## ១_ការថែទាំ :

ដំណាំប៉េងប៉ោះត្រូវការជីច្រើនប្រភេទ ដោយបែងចែកការប្រើប្រាស់ជីទៅតាមដំណាក់កាលលូតលាស់មានបួនដំណាក់កាល :

_ដំណាក់កាលទី១ :ប្រើប្រាស់ដោយទ្រាប់បាតដាក់នៅពេលភ្ជួររាស់ មុនពេលដាំឬស្ទូង ។

_ដំណាក់កាលទី២ :ពេលជ្រុំ និងពូនគល់ដំបូង គឺក្រោយពីដាំបាន ១០_១៥ ថ្ងៃ ដោយដាក់ជីអ៊ុយរ៉េ ៤៦% ចំនួន ៧០ គក្រ/ហ.ត ឬ យកទៅលាយទឹកស្រោចក៏បាន ។

_ដំណាក់កាលទី៣ : ពេលប៉េងប៉ោះមានអាយុកាលបាន ២៥_៣០ថ្ងៃ ត្រូវបន្ថែមជី ១៥_១៥_១៥ ចំនួន ២០០ គក្រ/ហ.ត ដោយជីកកប់ជីចំងាយពីគល់ ១០_១៥ ស.ម ធ្វើយ៉ាងណាកុំអោយដាច់ប្រព័ន្ធឫសរបស់វាដែលនាំឱ្យអន់ដើម ។

_ដំណាក់កាលទី៤ : ក្រោយពីប្រមូលផលបានមួយលើក បើដើមប៉េងប៉ោះមានការប្រែពណ៌ត្រូវថែមជី ១៥_១៥_១៥ ចំនួន ១០០ គក្រ/ហ.ត ទៀត ។

## _ការដោតចំណារ :

កសិករយើងមិនទំលាប់ប្រើដោតចំណារទេ គឺគាត់ដាំទុកឱ្យវារលើដី ដែលធ្វើអោយដើមមានភាពស្មោក សិប់ទ្រុបជាមួយស្មៅនិងងាយមានការបំផ្លាញពីសត្វល្អិតជាច្រើន ជាពិសេសដង្កូវចោះផ្លែនឹងធ្វើឱ្យផ្លែរលួយស្អុយច្រើន ដោយសារដើមដួលផ្លែប៉ះផ្ទាល់នឹងដី ។ ការដោតចំណារមានប្រសិទ្ធិភាពខ្ពស់ ពុំសូវមានការបំផ្លាញពីពពួកសត្វល្អិត និងងាយស្រួលក្នុងការថែទាំ បាញ់ថ្នាំនិងទទួលបានពន្លឺថ្ងៃគ្រប់គ្រាន់ ។

## _ការកាត់មែក :

ប៉េងប៉ោះជាប្រភេទដំណាំដែលមានដុះខ្នែងតាំងពីគល់ជាប់ដី រហូតដល់ផ្នែកខាងលើ ។ ចាំបាច់ត្រូវកាត់ខ្នែង ២_៣ ផ្នែកខាងក្រោមចោល ។ ការទុកខ្នែងច្រើនធ្វើឱ្យដើមប៉េងប៉ោះសិប់ទ្រុប លំបាកក្នុងការថែទាំនិងមានផ្លែតូច ។

## _ការស្រោចស្រព :

ដំណាំប៉េងប៉ោះជាដំណាំត្រូវការទឹកតិច ការបញ្ចូលទឹកត្រូវធ្វើឡើងដោយបញ្ចូលតាមចង្អូរចន្លោះរងក្នុងកំរិត ២/៣ នៃរង ។ បើស្រោចដោយប៉ោតមិនត្រូវឱ្យលិចគល់ឡើយ ។

## _សត្វល្អិតនិងជម្ងឺ :

ចាប់ពីពេលដាំរហូតដល់ពេលប្រមូលផលតែងតែមានការបំផ្លាញពីសត្វល្អិតតាមដំណាក់កាលលូតលាស់របស់ដំណាំប៉េងប៉ោះ ។ នៅក្នុងដំណាក់កាលលូតលាស់មានរងការបំផ្លាញដោយពពួកមមាច ប៉ុន្តែនៅក្នុងពេលចេញផ្កា និងផ្លែមានទទួលរងការបំផ្លាញពីពពួកដង្កូវចោះផ្លែ (Fruit worm) ដង្កូវហ្វូង ( Spodoptera litura ) ដង្កូវស៊ីជាលិកាស្លឹក ( Leaf miner ) នៅរដូវក្តៅមានការកើនឡើងយ៉ាងខ្លាំង ។

## _វិធានការការពារ :

ជំងឺផ្សិតច្រើនធ្វើឱ្យរលួយគល់ និងជំងឺចំណុចពណ៌ត្នោតនៅលើស្លឹក( Leaf-Mold ) ដោយអាកាសធាតុក្តៅហើយសើម ។ យើងត្រូវធ្វើអនាម័យចំការឱ្យបានស្អាត បាញ់ថ្នាំកំចាត់ ដូចជាឌីយ៉ាហ្សីណុង ( Diazinon ), ស្យូមីស៊ីឌីន ( Sumicidin ) ក្នុងកំរិត ២៥_៣០ សេសេ ( ១ សេសេ ស្មើនឹង ១ មីលីលីត្រ ) ក្នុងទឹក ២០ លីត្រ លាយជាមួយថ្នាំផ្សិតកាបតូម (Captom) ក្នុងកំរិត ១០_១៥ ក្រាម ។

_ដាំឱ្យសមស្របទៅតាមរដូវកាល

-រកពូជធន់

-ផ្លាស់ប្តូរមុខដំណាំ កុំដាំដំណាំដដែលៗ

-វិធីប្រើដើម្បីឱ្យមានប្រសិទ្ធិភាព គឺនៅពេលល្ងាចត្រជាក់ ពេលមេអំបៅឬដង្កូវចេញធ្វើសកម្មភាព ។

## ២-ការប្រមូលផល :

ក្រោយពីដាំបាន ៦០-៦៥ ថ្ងៃ នៅពេលដែលផ្លែប៉េងប៉ោះមានពណ៌សម្បុរក្រហមព្រឿងៗ យើងអាចបេះបាន ឬ ផ្លែចំណាស់បន្តិច និងអាចដឹកជញ្ជូនទៅឆ្ងាយបានដោយមិនបែក ។ គេអាចប្រមូលផលបានពី ៤-៨ ដង អាស្រ័យទៅតាមប្រភេទពូជ ។ ពូជកំណត់អាចប្រមូលបាន ៣ - ៤ ដង និង ពូជមិនកំណត់អាចប្រមូលផល ៥-៨ ដង ។ ការប្រមូលផលសំរាប់ទុកពូជ ត្រូវយកផ្លែទុំទី ១ ឬ ទី ២ ទើបជាការល្អ ។

ស្ថានីយ៍ក្បាលកោះបាន ធ្វើការសំរាំងពូជប៉េងប៉ោះបាន ២ ពូជ គឺ តេកាកា១ ( TKK១ ), តេតេកា២ ( TTK២ ) ។

-តេកាកា១ ( TKK១ )មានលក្ខណៈសម្បត្តិ ដើមដងទាប ធន់ នឹងជំងឺ សត្វល្អិត អាយុកាលលូតលាស់ខ្លី រយៈពេល ៨០ ថ្ងៃ ប្រមូលផលបាន មិនប្រកាន់រដូវ ផលិតផលទីផ្សារពេញនិយម មានសាច់ច្រើន ផ្លែមូលទ្រវែង ពណ៌សម្បុរល្អ ទិន្នផល មធ្យម ២៦-៣២ តោន ក្នុងមួយហិកតា ។

-តេតេកា២(TTK២) ដើមដងខ្ពស់ ការលូតលាស់មិនកំណត់ ធន់ នឹងជំងឺ សត្វល្អិត មិនប្រកាន់រដូវ អាយុកាលមធ្យម ៩០ ថ្ងៃ ផលិតផលទីផ្សារពេញនិយម ទិន្នផល ៣២- ៣៥ តោន ក្នុងមួយហិកតា ។

# ការថែទាំប៉េងប៉ោះ





គំរោងឥណទានកម្មវិធី ធនាគារ អភិវឌ្ឍន៍ អាស៊ី (ADB) លេខ 1445-CAM ( SF )

នាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម

លេខ : ៧ ឆ្នាំ ២០០២